# ឱកាសការងារសម្រាប់ការស្រាវជ្រាវអភិវឌ្ឍន៍

អង្គរស្រាវជ្រាវ និងផ្តល់ប្រឹក្សាបានបង្កើតឡើងឆ្នាំ២០១៣។ ជាក្រុមហ៊ុនមួយដែលបានចុះបញ្ជីនៅក្នុង ប្រទេសកម្ពុជា ដើម្បីផ្តល់ដំណោះស្រាយសំរាប់ការសិក្សាស្រាវជ្រាវដែលមានលក្ខណៈស្មុគស្មាញ និងសំនួរសម្រាប់គោលនយោបាយ។ បច្ចុប្បន្ន យើងខ្ញុំបាននឹងកំពុងជ្រើសរើស **បុគ្គលិកជនជាតិខ្មែរ** សម្រាប់បំរើការងារ ជាមួយក្រុមយើងខ្ញុំក្នុងតួនាទីជា៖

- **អ្នកសម្ភាសន៍ជាច្រើននាក់ (រយះពេលខ្លី)**
- **អ្នកវាស់កម្ពស់ ថ្លឹងទម្ងន់ជាច្រើននាក់ (រយៈពេលខ្លី)**

បេក្ខជនទាំងពីរភេទ ដែលអាចដាក់ពាក្យបានត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖

- មានបទពិសោធន៍សិក្សាស្រាវជ្រាវ មានការគ្រប់គ្រងគុណភាពការងារ ការប្រមូលទិន្នន័យ វាស់កំពស់ ថ្លឹងកុមារ និងបញ្ចូលទិន្នន័យ (ឧ៖ អ្នកសម្ភាសន៍ ប្រធានក្រុម អ្នកត្រួតពិនិត្យកម្រងសំណួរ អ្នកវាស់កំពស់ ថ្លឹងកុមារ អ្នកបញ្ចូលទិន្នន័យ )
- មានបទពិសោធន៍ធ្វើការជាមួយកុមារ (អាយុពី ២ ទៅ៥ឆ្នាំ) ជាផ្លូវការ ( ឧ៖ គ្រូមត្តេយ្យសាលា ជាដើម។ )
- កម្រិតនៃការសិក្សាអប់រំនៅសាកលវិទ្យាល័យដែលទាក់ទង នឹងការងារនេះ ឬក៏អ្នកសិក្សាអប់រំ ដែលមាន បទពិសោធន៍ពីមុនជាអ្នកស្រាវជ្រាវ អាចដាក់ពាក្យបាន។
- មានបទពិសោធន៍ធ្លាប់ប្រើទូរស័ព្ទស្មាតហ្វូន និងចេះវាយអក្សរជាខ្មែរយូនីកូដកាន់តែប្រសើរ
- ត្រូវទំនេរអាចធ្វើដំណើរ និងធ្វើការ ពីខែមិនា ដល់ខែឧសភា ឆ្នាំ២០១៧ (ប្រហែលជា២ខែ)។
- ត្រូវមានភាពរួសរាយរាក់ទាក់ ប្រឹងប្រែងធ្វើការងារ អាចធ្វើការជាក្រុម និងអាចធ្វើការក្នុងស្ថានភាព លំបាកបាន។
- ត្រូវគោរពគោលការណ៍ក្រមសីលធម៌អង្គរស្រាវជ្រាវ ប្រកបដោយតម្លាភាព និងការទទួលខុសត្រូវ។

បើបេក្ខជនមានចំណាប់អារម្មណ៍ សូមដាក់ CV និង Cover letter រួមទាំងអ្នកធានា (references) ចំនួនពីរនាក់។ សូមដាក់ពាក្យមកកាន់ការិយាល័យ**អង្គរស្រាវជ្រាវ ផ្ទះលេខ ៧A ផ្លូវលេខ ១៧៣ សង្កាត់ ទួលទំពូង២ ខ័ណ្ឌចំការមន ភ្នំពេញ ឬតាមរយៈសារអេឡិចត្រូនិច៖** inquiries@angkorresearch.com

កាលបរិច្ឆេទឈប់ទទួលពាក្យនៅម៉ោង **៤: ៣០នាទី រសៀល ថ្ងៃព្រហស្បតិ៍ ទី២៣ ខែ មិនា ឆ្នាំ២០១៧។**

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមក **លោក. ឃឹម សារុន** តាមទូរស័ព្ទលេខ ០២៣ ២២២ ៥០១ ឬតាមរយៈគេហទំព័រ www.angkorresearch.com.

ភ្នំពេញ ថ្ងៃទី១៦ ខែ មិនា ឆ្នាំ ២០១៧

នាយកប្រតិបត្តិ

Ian Ramage

**Angkor Research and Consulting Ltd.**
No. 7A Street 173, Toul Tumpoung II, Chamkarmon, Phnom Penh, Cambodia
Tel. (+855) 23-222-501 inquiries@angkorresearch.com